ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រែក្លាយសាលានាយទាហានចម្រុះ

## ទៅជា វិទ្យាស្ថានជាតិយោធា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃ០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី លក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃ១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩

សម្រេច

មាត្រា ១.

ត្រូវបានប្រែក្លាយសាលានាយទាហានចម្រុះ ទៅជាវិទ្យាស្ថានទ័ពជើងគោក មានកម្រិតស្មើគ្រឹះស្ថានឧត្តមសិក្សា។ វិទ្យាស្ថានទ័ពជើងគោក សរសេរអក្សរកាត់ថា វ.ឧ.ជ.គ ។ វ.ឧ.ជ.គ មានទីតាំងបច្ចុប្បន្ននៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

មាត្រា ២.

វិទ្យាស្ថានទ័ពជើងគោក មានតួនាទីនិងភារកិច្ចបណ្តុះបណ្តាល នាយទាហានបឋមទ័ពជើងគោក និងស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេសយោធា ចំណេះដឹងទូទៅដល់កម្រិត បរិញ្ញាបត្ររង បរិញ្ញាបត្រ និងវិក្រឹតការ លើមុខជំនាញកងទ័ពជើងគោក ។ វ.ឧ.ជ.គ ត្រូវរៀបចំកម្មវិធីសិក្សាគ្រប់កម្រិត និងគ្រប់មុខជំនាញតាមផែនការរបស់ក្រសួងការពារជាតិ។

មាត្រា ៣.

វិទ្យាស្ថានទ័ពជើងគោក ស្ថិតនៅក្រោមការគ្រប់គ្រង របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ។ វិទ្យាស្ថានទ័ពជើងគោក ដឹកនាំដោយនាយកមួយរូប និងនាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់។

មាត្រា ៤.

វិទ្យាស្ថានទ័ពជើងគោក មានថ្នាក់បណ្តុះបណ្តាល និងវគ្គវិក្រឹតការនាយទាហានបឋមទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ តាមមុខជំនាញ ដូចខាងក្រោម ៖

- បញ្ជាការ ថ្មើរជើង
- បញ្ជាការ ស៊ើបការ
- បញ្ជាការ រថក្រោះ រថពាសដែក
- បញ្ជាការ កាំភ្លើងធំ
- បញ្ជាការ ការពារអាកាស
- បញ្ជាការ វិស្វកម្ម
- បញ្ជាការ បញ្ជូនសារ
- បញ្ជាការ គីមីសាស្ត្រ
- បញ្ជាការ ការពារព្រំដែន។

ទៅអនាគត យោងតាមសេចក្តីត្រូវការចាំបាច់ក្នុងវិស័យការពារជាតិ វិទ្យាស្ថាននេះ អាចបន្ថែមមុខជំនាញដទៃទៀត ដោយអនុលោមតាមមាត្រា ២ នៃអនុក្រឹត្យនេះ។

មាត្រា ៥.

លក្ខខណ្ឌជ្រើសរើស សិស្ស និស្សិត និងយោធិន ឱ្យចូលសិក្សានៅវិទ្យាស្ថានទ័ពជើងគោក ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ឱ្យបានសមស្របទៅតាមបទដ្ឋាន ស្តីពីការកំណត់លក្ខខណ្ឌ នៃការចូលរៀននៅឧត្តមសិក្សា និងមធ្យមសិក្សាឯកទេស។

មាត្រា ៦.

និស្សិតនាយទាហានបឋម ដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថានទ័ពជើងគោក ហើយបានប្រឡងបញ្ចប់ការសិក្សាដោយជោគជ័យត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញដែលបានសិក្សា។

សញ្ញាបត្របញ្ចប់ការសិក្សា នៃវិទ្យាស្ថានទ័ពជើងគោក មានតម្លៃសមមូល បរិញ្ញាបត្ររងនៃកម្រិតបណ្តុះបណ្តាល នៅគ្រឹះស្ថានឧត្តមសិក្សា។

សញ្ញាបត្រនេះ ត្រូវចុះហត្ថលេខាដោយនាយកវិទ្យាស្ថានទ័ពជើងគោក និង រដ្ឋមន្ត្រីក្រសួងការពារជាតិ។

មាត្រា ៧.

ក្រសួងការពារជាតិ ក្រសួងអប់រំ យុវជន និងកីឡា និងគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ត្រូវ សហការក្នុងការរៀបចំកម្មសិក្សា និងជ្រើសរើសគ្រូឧត្តមសិក្សា និងសាស្ត្រាចារ្យ មកបង្រៀននៅវិទ្យាស្ថានទ័ពជើងគោក តាមតម្រូវការ និងភារកិច្ចបណ្តុះបណ្តាលធនធានមនុស្ស ក្នុងកងយោធពលខេមរភូមិន្ទ។

មាត្រា ៨.

ការរៀបចំ និងការប្រព្រឹត្តទៅ នៃវិទ្យាស្ថានទ័ពជើងគោក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងការពារជាតិ។

មាត្រា ៩.

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ១០.

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមានត្រា ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ